# បុព្វបទ*

*សៀវភៅកម្រងខេមរសិក្សានេះ ជាប្រជុំអត្ថបទសិក្សា ដែលបដិសន្ធិឡើង ដោយមិត្តនិងអ្នករាប់អានសាស្ត្រាចារ្យបណ្ឌិតទាំងបីរូប គឺ បណ្ឌិតសភាចារ្យ ឃីន សុខ, សាស្ត្រាចារ្យបណ្ឌិត ឃួន សុខម្ភូ និងបណ្ឌិត្យសភាចារ្យ ឡុង សៀម ។*

*អ្នកចូលរួមក្នុងការតាក់តែងសៀវភៅរួមនេះ មានចេតនាប្រាថ្នាឧទ្ទិសអត្ថបទសិក្សាខ្លួនម្នាក់ៗ ជូនវិញ្ញាណក្ខន្ធលោកទាំងបីរូប ដែលបានបូជាកម្លាំងកាយកម្លាំងចិត្ត ក្នុងជីវិតលោកិយលោក ដើម្បីបម្រើប្រទេសជាតិក្នុងវិស័យវប្បធម៌អរិយធម៌ខ្មែរ ។ យើងទាំងអស់គ្នាមិនភ្លេចឧបការគុណលោក ដែលទុកស្នាដៃស្រាវជ្រាវជាច្រើន បន្សល់ជាកេរ្តិ៍ឱ្យកូនខ្មែរជំនាន់ក្រោយសិក្សាទៅអនាគត ។ រូបកាយលោកបាត់ទៅ តែកេរ្តិ៍ឈ្មោះនៅជាអមតៈក្នុងខេមរសិក្សា ។*

*សៀវភៅរួមនេះចែកជាប្រាំមួយចង្កោម គឺ ៖*

**១) ជីវប្រវត្តិ**

*ជីវប្រវត្តិសង្ខេបលោកសាស្ត្រាចារ្យបណ្ឌិតទាំង ៣ រូប បានរៀបរៀងឡើង ដោយបណ្ឌិតសភាចារ្យ* **ឃីង ហុកឌី** *តាមទិន្នន័យនិងឯកសារនានា ដែលមានរក្សាទុកក្នុងបណ្ណសារផ្ទាល់ខ្លួន ។*

**២) ភាសា**

*ក្នុងចង្កោមភាសាវិជ្ជា មានវិភាគទានអត្ថបទសិក្សាសាស្ត្រាចារ្យបណ្ឌិត* **មីស្អែល បុក្ទី អង់តែល្ម** *ជាអតីតសិស្សជំនិតរបស់បណ្ឌិតសភាចារ្យ* **ឃីន សុខ** *។ អត្ថបទនេះស្តីពីការសិក្សាលើពាក្យពីរម៉ាត់ គឺ ៖ « ពាក្យវង្វាល់ "ថ្ងង" និង " ទ្នាលិ" ក្នុងភាសាខ្មែរបុរាណ និងកម្ចាយរបស់ពាក្យទាំងពីរនេះក្នុងភាសា*

---

* *សូមអរគុណចំពោះសាស្ត្រាចារ្យបណ្ឌិត* មីស្អែល បុក្ទី អង់តែល្ម *ដែលបានជួយផ្នែកបច្ចេកទេស និងបានជួយពិនិត្យអត្ថបទសិក្សាក្នុងកម្រងខេមរសិក្សានេះ ។*

ខ្មែរទំនើប» ។ ចំពោះការសិក្សាពាក្យពីរម៉ាត់នេះ លោកបានប្រៀបធៀបមើលទៅនឹងពាក្យដែលមាននៅក្នុងគ្រាមភាសាខ្មែរសុរិន្ទ និងភាសាប្រទេសជិតខាង ដូចជា ភាសាសៀម, ភាសាលាវ និងភាសាមន ជាដើម ។ ក្នុងចង្កោមភាសានេះ មានវិភាគទាន ១ ទៀតរបស់បណ្ឌិតសភាចារ្យ ពុំ ម៉ល់ ស្ដី «អំពីសញ្ញាប្រយោគចម្រូងចម្រាសមួយចំនួន ក្នុងភាសាខ្មែរបច្ចុប្បន្ន» ដូចជា ការប្រើដំណកឃ្លានិងសញ្ញាក្បៀស ជាដើម ។ បណ្ឌិតសភាចារ្យរូបនេះ បានស្គាល់និងរាប់អានបណ្ឌិតសភាចារ្យ **ឃីង សុខ**, សាស្ត្រាចារ្យបណ្ឌិត **ឃ្លូង សុខម្ហ** និង បណ្ឌិតសភាចារ្យ **ឡុង សៀម** ជាយូរឆ្នាំមុនលោកចែកឋាន ។

## ៣. វប្បធម៌ ជំនឿ និងពុទ្ធសាសនា

ក្នុងចង្កោមធំនេះ មានអត្ថបទសិក្សាសាស្ត្រាចារ្យប្រវត្តិសាស្ត្រ **វង់ សុជាតា** ជាអ្នកជំនាញផ្នែកសិលាចារឹកខ្មែរបុរាណនិងខ្មែរកណ្ដាល ហើយលោកជាអតីតសិស្សជំនិតបណ្ឌិតសភាចារ្យ **ឡុង សៀម** ដែលបន្តការសិក្សាស្រាវជ្រាវតាមគន្លងគ្រូលោក ។ អត្ថបទស្រាវជ្រាវនេះមានចំណងជើងថា ៖ «លិង្គាទ្រិឬលិង្គបព៌តនៃលិង្គបុរៈនៅកម្ពុជា» ។ លោកលើកយកប្រធានបទនេះ មករួបរួមក្នុងសៀវភៅនេះ ដោយសារលោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម និង ឃីន សុខ ចាប់អារម្មណ៍ចំពោះលិង្គបព៌តនៅភ្នំព្រះជាតុនេះដែរ ។ មុនពេលស្លាប់នៅរវាងឆ្នាំ ២០០៤–២០០៥ លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម មានក្ដីរំភើបណាស់ នៅពេលបានឃើញភ្នំព្រះជាតុ តាមរយៈរូបថតជាច្រើនសន្លឹក និងឯកសារពាក់ព័ន្ធ ដែលលោកបានបង្ហាញជូនគាត់ ។ ប៉ុន្តែ ដោយសារគាត់គ្មានពេលវេលាច្រើន ទើបមិនអាចទស្សនាភ្នំនេះបាន តាមការអញ្ជើញរបស់លោក ។ ចំណែកលោកសាស្ត្រាចារ្យបណ្ឌិត ឃីន សុខ ក៏ដូចគ្នានោះដែរ គាត់មានការចាប់អារម្មណ៍ និងស្ងើចសរសើរចំពោះគំនិតច្នៃប្រឌិតរបស់ដូនតាខ្មែរ ដែលបានចាត់ទុកដុំថ្មបន្តើតលើកំពូលភ្នំមួយនេះ ដូចជាសិវលិង្គពីធម្មជាតិដ៏ធំមួយ នៅពេលគាត់បានអញ្ជើញទៅទស្សនាភ្នំព្រះជាតុនេះផ្ទាល់ នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៤ និងនៅពេលគាត់បានដឹងអំពីឯកសារមួយចំនួន ដែលពាក់ព័ន្ធនឹងអត្ថិភាពសំណង់សក្ការៈនៃភ្នំនេះ កាលពីសម័យមុន

*អង្គរ និង អង្គរ តាមរយៈការបង្ហាញជូនរបស់លោក ។ លោកសាស្ត្រាចារ្យ ឃឹន សុខ ថែមទាំងបានយករឿងលិង្គបព៌តនេះ ទៅផ្សព្វផ្សាយប្រាប់សាស្ត្រាចារ្យប្រវត្តិវិទ្យាមួយចំនួននៅថ្នាក់វិទ្យាល័យ ដែលគាត់បានបង្រៀនទៀតផង ។ ដើម្បីរំឭកអនុស្សាវរីយ៍នេះឡើងវិញ ទើបលោកលើកយកប្រធានបទនេះ មកបញ្ចូលក្នុងសៀវភៅឧទ្ទិសស្នាដៃជូនលោកគ្រូទាំងបីនេះឯង ។ នៅទីបញ្ចប់ លោកទាញយោបល់រួមថា ៖*

« នាមដែលមានអត្ថន័យដូចគ្នាទាំងពីរ គឺ លិង្គាទ្រិ និង លិង្គបព៌ត នៃអាទិទេពស្រីភទ្រេស្វរៈដ៏ល្បីល្បាញ ប្រហែលជាតាំងនៅកន្លែងពីរដាច់ដោយឡែកពីគ្នា គឺ វត្តភូ និងភ្នំព្រះធាតុនេះឯង ។»

*ក្នុងចង្កោមនេះ លោក* **ច័ន្ទ វិត្ថារ៉ុង** *ជាអតីតសិស្សសិលាចារឹកខ្មែររបស់បណ្ឌិតសភាចារ្យ* **ឡុង សៀម** *។ លោកជាស្ថាបត្យករធ្វើការនៅក្រុងសៀមរាប បានធ្វើវិភាគទានអត្ថបទសិក្សាមួយស្តីពី « ព្រះធាតុ តួនាទីប្រាសាទក្នុងសម័យក្រោយអង្គរ » ។ ជាសេចក្តីសង្ខេប លោកបញ្ជាក់ថា ៖*

« "ព្រះធាតុ" គឺជាការហៅប្រាសាទ (ឬបូជនីយដ្ឋាន) មួយចំនួន ពេលបច្ចុប្បន្ន ដែលបន្សល់ពីផ្លែផ្កានៃការលូតលាស់រុងរឿង របស់ពុទ្ធសាសនាថេរវាទនៅសម័យក្រោយអង្គរ ។ ស្ថាបត្យកម្មជាទេវាល័យក្នុងទ្រឹស្តីព្រហ្មញ្ញសាសនា និង ពុទ្ធសាសនាមហាយាន បានកែប្រែជា "ព្រះធាតុ" ដែលអ្នកស្រុកជឿថា មានបញ្ចុះ "ព្រះមហាសារីរិកធាតុ" ឬ ជានិមិត្តរូបនៃ "បរិនិព្វាន" ។

ព្រះមហាសារីរិកធាតុបានបង្ហាញឥទ្ធិពល ក្នុងប្រព័ន្ធជំនឿនៃពុទ្ធសាសនិកខ្មែរតាមបែបប្រពៃណី ដោយមានភ្ជាប់ទំនាក់ទំនងជាមួយនឹងព្រះរាជាខ្មែរ ។ម្យ៉ាងទៀត ជនជាតិខ្មែរយល់ថា ព្រះមហាសារីរិកធាតុអាចនាំសេចក្តីសុខដុមរមនាដល់ប្រទេសជាតិ និង ប្រជារាស្ត្រ ឬ គេអាចនិយាយបានម្យ៉ាងទៀតថា ព្រះសារីរិកធាតុជានិមិត្តរូបនៃតុល្យភាពសង្គម និង ឯកភាពជាតិ ដែលប្រកបដោយការការពារ និង និរន្តភាពនៃពុទ្ធសាសនា ។»

*បណ្ឌិតសភាចារ្យ* **ជោង ដែល** *បានសិក្សាស្រាវជ្រាវលើព្រះពុទ្ធសាសនាក្នុងទសវត្សក្រោយនេះ ដោយលោកធ្វើជាពិធីកររៀងរាល់សប្តាហ៍ តាមប្រព័ន្ធពត៌មានវិទ្យា « ស្កាយ »* (Skype) *និង « ផល់ថក »* (Paltalk) *ស្តីពីព្រះ*

*ត្រៃបិដកនិងភាសាបាលី ។ លោកបានធ្វើវិភាគទាន ២ ក្នុងផ្នែកព្រះពុទ្ធ-សាសនា ។ អត្ថបទសិក្សាទី ១ ស្តីពី «ព្រះសទ្ធម្មដែលពុទ្ធបរិស័ទគប្បីដឹងជាដំបូង» បានចែកការស្រាវជ្រាវនេះជា ២ អត្ថបទ ៖*

«អត្ថបទទី ១ នេះ ចែកចេញជាពីរផ្នែក ។ ផ្នែកទី ១ ស្តីអំពីបច្ចេកទេសថ្លឹងថ្លែងពិចារណារកហេតុផល ១០ យ៉ាង ចំពោះព័ត៌មានដែលបានទទួល ឬ ព្រឹត្តិការណ៍ផ្សេងៗ ដែលកើតឡើង ហើយយើងបានដឹង ។ បច្ចេកទេសនេះ គឺជាចម្លើយរបស់ព្រះពុទ្ធ ដែលឆ្លើយទៅនឹងសំនួរពួកកាលាមក្សត្រិយ៍ ថា “បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះ មានសេចក្តីងឿងឆ្ងល់សង្ស័យពេកណាស់ ចុះបណ្តាសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ អ្នកណានិយាយពិត អ្នកណានិយាយកុហក” ។ ផ្នែកទី ២ គឺជា ការបង្រៀនរបស់ព្រះពុទ្ធ ស្តីអំពីការចំណាយពេលវេលារបស់បុថុជ្ជន ក្នុងការរលឹកដល់រឿងអតីតនិងរឿងអនាគត ។ ព្រះអង្គទ្រង់ទូន្មានថា បុថុជ្ជន គប្បីផ្តោតនិងចំណាយពេលេវេលាគិតដល់ និងយកចិត្តទុកដាក់ លើព្រឹត្តិការណ៍បច្ចុប្បន្នជាចម្បង ។»

*បណ្ឌិតសភាចារ្យ* ដែល ចោជ *បានបង្ហាញទិដ្ឋភាពទូទៅនៃ «សេដ្ឋកិច្ចព្រះពុទ្ធសាសនានិងមូលធននិយម» ដូចបានពោលតទៅនេះ ៖*

«សង្គមមនុស្សមានការអភិវឌ្ឍន៍ ពីភាពសាមញ្ញងាយៗ ក្នុងការរស់នៅ ត្រឹមតែការបំពេញក្រពះ ដូចជា ជនជាតិដើមនៃប្រទេសអូស្ត្រាលី គឺរកមួយពេលបរិភោគមួយពេលដោយគ្មានការសន្សំទុក ។ នេះគឺជាជីវភាពងាយស្រួលរបស់សង្គមមនុស្ស ដែលមិនបង្កើតនូវកង្វល់ក្នុងការខ្វះខាតនៃជីវិតប្រចាំថ្ងៃ ។ ធនធានសំរាប់រស់នៅប្រចាំថ្ងៃ ត្រូវបានទុកឲ្យបរិដ្ឋានធម្មជាតិថែរក្សាឲ្យដោយប្រពៃ គឺគុណភាព និងបរិមាណ នៅមានដដែលដូចដើម ។ កាលបើសង្គមមនុស្សមានការរីកធំឡើងដោយចំនួននៃសមាជិកច្រើន ក៏ក្លាយទៅជាសង្គមសមូហភាព ដែលតម្រូវឲ្យបង្កើតនូវបណ្តាញនិងប្រព័ន្ធផ្សេងៗ ដើម្បីទ្រទ្រង់ជីវភាពប្រភេទនោះទៅតាមសម័យកាល ។ បណ្តាញនិងប្រព័ន្ធផ្សេងៗ នោះ មាន ប្រព័ន្ធគមនាគមន៍សំរាប់ដឹកជញ្ជូនស្បៀង ប្រព័ន្ធសុខាភិបាល ប្រព័ន្ធសេដ្ឋកិច្ច ជាដើម ។ បណ្តាញនិងប្រព័ន្ធផ្សេងៗ ទាំងនោះ បង្កើតសំរាប់តម្រូវការនៅពេលនោះ លុះដល់ពេលក្រោយ បណ្តាញនិងប្រព័ន្ធផ្សេងៗ ទាំងនោះ ក្លាយទៅជាប្រើការលែង

កើត ។ យើងបានដឹងហើយថា ក្នុងកាលកន្លងផុតទៅនោះ បណ្ដាញនិងប្រព័ន្ធសេដ្ឋកិច្ច នៃរបបកុម្មុយនិស ត្រូវបានវិនាសបាត់បង់ ដោយសារតែបរាជ័យនៃរបបសេដ្ឋកិច្ច ដែលពុំអាចទ្រទ្រង់តម្រូវការ សំរាប់រស់នៅ ដែលក្នុងព្រះពុទ្ធសាសនា គេបានស្គាល់ថា ចតុបច្ច័យ (បច្ច័យ ៤) ម្ហូបអាហារ សម្លៀកបំពាក់ ទីលំនៅ និងថ្នាំពេទ្យ ។ ឥឡូវនេះ របបសេដ្ឋកិច្ចធំមួយ ដែលមានឈ្មោះថា មូលធននិយម នោះ ត្រូវរង្គោះរង្គើដែរ ក្នុងន័យថា បណ្ដាញនិងប្រព័ន្ធសេដ្ឋកិច្ច ដែលគេសង្ឃឹមថា នឹងបានផ្ដល់នូវសុខុមាលភាពជានិច្ចនោះ បានផ្ដល់នូវសញ្ញាថា មានការទ្រុឌទ្រោមនិងអសមត្ថភាព ក្នុងការផ្ដល់នូវសេចក្ដីរីករាយសប្បាយ ដូចដែលបានធ្លាប់សង្ឃឹមទុកនោះ ។ ប្រវត្តិនៃការបាត់បង់ធនធានធម្មជាតិ ដោយសារចរិត មាយា និងអវិជ្ជាលោភលន់ របស់មនុស្សលោក មានចែងក្នុងប្រវត្តិព្រះពុទ្ធសាសនា ក្នុងសម័យដើមនៃប្រវត្តិសាស្ត្រមនុស្សលោក ដូចបានចែងក្នុងគម្ពីរ មហាវង្ស និងគម្ពីរ មនុធម្មជាតុ ប្រទេសសិរីលង្កានិងភូមា ។ »

*អ្នកស្រីសាស្ត្រាចារ្យបណ្ឌិត* **ប៉ែន សេដ្ឋារិត** *ជាសាស្ត្រាចារ្យភាសាខ្មែរក្នុងឧត្តមសិក្សានៅប្រទេសជប៉ុន បានធ្វើការសិក្សាស្រាវជ្រាវប្រៀបធៀបក្នុង « រឿងនិទានដែលទាក់ទងនឹងរូបរបស់ជប៉ុននិងនាគរបស់ខ្មែរ» ។*

*បណ្ឌិតសភាចារ្យ* **ម៉ាក់ ភឹង** *ជាអតីតនាយកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ ក្រុងប៉ារីស ប្រទេសបារាំង បានចូលរួមវិភាគទានអត្ថបទសិក្សាមួយជាភាសាបារាំង ស្ដីពី « ទិដ្ឋភាពខ្លះៗ នៃជំនឿសាសនា ទាក់ទងពាក់ព័ន្ធនឹងសង្គ្រាមរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសសៀម (ស.វ. ទី ១៥–១៩)»* (« Quelques aspects des croyances religieuses liées aux guerres entre le Cambodge et le Siam (XVe–XIXe siècles) ») ។

**៤) អក្សរសិល្ប៍**

*ក្នុងចង្កោមអក្សរសិល្ប៍ខ្មែរនេះ បណ្ឌិតសភាចារ្យ* **ឃីង ហុកឌី** *បានចូលរួមវិភាគទានអត្ថបទសិក្សា ២ គឺ ១ ស្ដីពី «ស្ត្រីគ្រប់លក្ខណ៍ក្នុងអក្សរសិល្ប៍ខ្មែរ» ដោយបានបង្ហាញការពណ៌នាពីស្ត្រីគ្រប់លក្ខណ៍ក្នុងរឿងព្រេងប្រជាប្រិយ, រឿងល្បែង និងច្បាប់ផ្សេងជាដើម ហើយ ១ ទៀត ស្ដីពី «ដំណើរប្រតិកូ*

**សើន ដៀប** *នៅក្រុងប៉ារីស នាឆ្នាំ ១៩០០» ។ ក្នុងអត្ថបទទី ២ នេះ មានពណ៌នាពីដំណើរលោក* **សើន ដៀប** *ក្នុងតំណែងលោកជាចៅហ្វាយស្រុកនៅស្រុកទ្រាំងនៅកម្ពុជាក្រោម ។ លោកចេះភាសាបារាំងយ៉ាងច្បាស់លាស់ ព្រោះលោកធ្លាប់បានសិក្សាភាសាបារាំងជាមួយលោកសង្ឃកាតូលិក ហើយលោកធ្លាប់ធ្វើជាលេខានិងជាអ្នកបកប្រែភាសាខ្មែរទៅជាភាសាបារាំង ហើយលោកបានជួយធ្វើវចនានុក្រមខ្មែរ-បារាំងឱ្យលោក អេម៉ែន អៃម៉ូនីញេ និងកិច្ចការស្រាវជ្រាវឯទៀតៗ ។ នាពេលលោកមកប៉ារីស ក្នុងតួនាទីជាប្រតិភូមកចូលរួមពិធីតាំងតុអន្តរជាតិក្នុងឆ្នាំ ១៩០០ ហើយ លោកក៏បានតែងកំណាព្យ ១ ដែលជាប្រភេទ «និរាស» ។*

*ក្នុងចង្កោមនេះ បណ្ឌិតសភាចារ្យ* **ផែល ចោជ** *ក៏បានចូលរួមវិភាគទាន ១ ទៀត ស្តីពី «លំអនាងសីតាតាមរយៈអក្សរសិល្ប៍និងចម្លាក់ខ្មែរ» ។ ក្នុងប្រធានបទនេះ លោកបានសិក្សាលើអក្សរសិល្ប៍ជាសំដីនិងអក្សរសិល្ប៍ជាសំណេរ ដូចលោកបានបញ្ជាក់ក្នុងអត្ថបទសិក្សាលោក ៖*

«រឿងរាមកេរ្តិ៍ខ្មែរមានក្នុងទម្រង់និយាយផ្ទាល់មាត់ អត្ថបទសរសេរ សិលាចារឹក របាំល្ខោនខោល និងណាំងស្បែក ។ ក្នុងអត្ថបទនេះ ខ្ញុំសំអាងលើរឿងនិយាយផ្ទាល់មាត់ អត្ថបទសរសេរ និងចម្លាក់លើថ្ម ដើម្បីសាកល្បងសិក្សាលំអផ្លូវកាយ និងចរិយារបស់នាងសីតា ។ អត្ថបទនេះផ្តើមដោយការរៀបរាប់ជីវិតនាងសីតា កាលនៅជាជាយារបស់ព្រះឥន្ទ្រ មុនពេលយោនយកកំណើតជាមនុស្ស ។ ហេតុផលដែលបណ្តាលឲ្យនាងសីតាមកចាប់ជាតិជាមនុស្សនេះ ក៏បានជាកត្តាមួយនៃចម្បាំងរបស់ព្រះរាម តទល់នឹងក្រុងរាពណ៍ដែរ ។

អត្ថបទខ្លីនេះ ចែកជាបីចំណែក ។ ចំណែកទី ១ ជាការប្រៀបធៀបបែបបទពិពណ៌នាលំអនាងសីតា តាមរូបរាងកាយនិងចរិយាសម្បត្តិ ដែលមានក្នុងអត្ថបទរបស់ឥសី វាល្មីកិ ទៅនឹងអត្ថបទរាមកេរ្តិ៍ខ្មែរផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ និងឯកសារខ្មែរផ្សេងទៀត ។ ចំណែកទី ២ ជាការប្រៀបធៀបបែបបទពិពណ៌នាលំអនាងសីតា ក្នុងអត្ថបទរបស់ឥសី វាល្មីកិ ទៅនឹងអត្ថបទរាមកេរ្តិ៍ក្នុងអក្សរសិល្ប៍នៃនគរជិតខាង ។ ចំណែកទី ៣ គឺជាចម្លើយតបទៅនឹងសំនួរថា តើអត្ថបទរឿង

រាមកេរ្តិ៍ខ្មែរ បានឆ្លុះបញ្ចាំងស្នាដៃដ៏ស្ទាត់ជំនាញនៃសិល្បករខ្មែរឬទេ តាមចម្លាក់លើថ្មក្នុងអតីតកាល ។

ដោយផ្អែកទៅលើការប្រៀបធៀបសំអាងលើភាសាខ្មែរ អ្នកនិពន្ធមានបំណងទី ១ គឺការសន្និដ្ឋានខ្លះៗ ស្តីពីសម័យកាលនៃការសរសេរ និងការនិទានរឿងរាមកេរ្តិ៍ខ្មែរ តាមឯកសារដែលមាននៅក្នុងដៃ ។ ទី ២ អ្នកនិពន្ធរៀបរាប់ដោយសង្ខេបស្តីពីលំអផ្នែកចរិយារបស់ស្ត្រីជាភរិយានៃអ្នកជំនួយការសំខាន់ៗ ផ្សេងៗ ទៀតរបស់ព្រះរាមនិងក្រុងរាពណ៍ ដើម្បីជាកិច្ចគាំទ្រដល់ចរិយាសម្បត្តិដ៏ល្អឥតខ្ចោះរបស់នាងសីតា ។ បំណងទី ៣ អ្នកនិពន្ធធ្វើការសន្និដ្ឋានថា នាងសីតាមានលក្ខណៈបរិបូណ៌ ជាតំណាងស្ត្រីខ្មែរផ្នែកលំអផ្លូវកាយនិងផ្នែកចរិយា ក្នុងគ្រាលំបាកបំផុតនៃជីវិតក្នុងពេលសង្គ្រាម ។ នៅទីបញ្ចប់ អ្នកនិពន្ធគាំទ្រសកម្មភាពនិងគតិយុត្តិធម៌របស់ព្រះធរណី ដែលជាមាតារបស់នាងសីតា ក្នុងការជួយដោះស្រាយនាង ឲ្យរួចផុតទុក្ខលំបាក ក្នុងទំនាក់ទំនងជាមួយព្រះរាម ដើម្បីរក្សាកិត្តិយសជាស្ត្រីគ្រប់លក្ខណ៍ ។ អ្នកនិពន្ធខ្មែរគាំទ្រភាពបរិសុទ្ធរបស់នាងសីតាតាំងពីដំបូងរហូតដល់ចប់ ដោយបដិសេធអំពើអយុត្តិធម៌របស់ព្រះរាម ដែលជាតំណាងព្រះវិស្ណុនៅឋានមនុស្សលោក ។»

**៥) នយោបាយ**

*ក្នុងចង្កោមសិក្សាកថាផ្នែកនយោបាយ បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ បានផ្តល់អត្ថបទ ២ ជាភាសាបារាំង ៖*

– « *កម្ពុជាឈមមុខទល់នឹងបរិបទជុំវិញប្រទេស* » « Le Cambodge face à son environnement » ។

– « *ការត្រិះរិះលើទិដ្ឋភាពខ្លះៗ នៃទំនាក់ទំនងរវាងកម្ពុជា និង សហរដ្ឋអាមេរិក* » « Réflexions sur certains aspects des relations entre le Cambodge et les États-Unis d’Amérique » ។

**៦) អនុស្សាវរីយ៍**

*ដើម្បីបិទទំព័រសៀវភៅរួមនេះ លោក* **អ៊ុច កិរម្យ** *ជាប្រធានពុទ្ធិកមណ្ឌលខ្មែរនៅសហរដ្ឋអាមេរិក បានបង្ហាញ «និស្ស័យរវាងលោកសាស្ត្រាចារ្យបណ្ឌិត ឃីន សុខ នឹងខ្លួនលោក» ។*

រូបកាយចាត់ជៅ តែកិត្តិជាមលោកជៅជាអមតៈ ។

*បណ្ឌិតសភាចារ្យ* **ឃីង ហុកឌី**
*កូលេស្សៀង, ថ្ងៃទី ១៦ សីហា ២០១២*